ព្រឹត្តិបត្រពាណិជ្ជកម្ម
iTrade Bulletin

Inside

Infographic
"E-commerce Ecosystem & Statistics"

Local & Global News

Opinion Paper
"In the absence of global rule,
justifications of anti-circumvention measures questioned"
Mr. Bunthorn SOK & Mr. Tola CHINKET

វ៉ុលទី០២ | លេខទី០២ | ខែសីហា ឆ្នាំ២០២២
VOLUME 02 | ISSUE 02 | AUGUST 2022

ប្រព័ន្ធអេកូឡូស៊ី និងស្ថិតិនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

THIRD EDITION

សូមស្កេនដើម្បីទាញយកព្រឹត្តិបត្រពាណិជ្ជកម្ម

EIF Enhanced Integrated Framework

Go4eCAM Project

គម្រោងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកថ្នាក់ជាតិដំបូងគេបង្អស់នៅកម្ពុជា បង្កើតឡើងក្នុងគោលបំណងបង្កើនឱកាសសេដ្ឋកិច្ចសម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាបានចូលរួមក្នុងសេដ្ឋកិច្ចតាមបែបឌីជីថល។

CAMBODIATRADE

បង្កើតផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក B2B2C ដែលហៅថា **CAMBODIATRADE** (cambodiatrade.com)

ផ្តល់ជំនាញ និងសហគ្រិនភាពសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដល់សហគ្រាសធុនតូចនិងមធ្យម

ការទទួលបានហិរញ្ញវត្ថុ (វេទិការិនិយោគិន)

សមាសភាពនៃគម្រោង Go4eCAM

សមាសភាគទី១

ផ្សារពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកខេមបូឌាត្រេដ

- បើកសម្ពោធដំណើរការជាផ្លូវការក្រោមអធិបតីភាពរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២
- ចូលរួមនិងប្រើប្រាស់ដោយឥតគិតថ្លៃសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងការដាក់លក់ផលិតផលទាំងទីផ្សារក្នុងស្រុកនិងក្រៅស្រុក
- សហគ្រាសធុនតូចនិងមធ្យមជាង ១៣០ ក្រុមហ៊ុន ត្រូវបានអនុញ្ញាតចូលរួម និងមានផលិតផលជាង ១.២០០បានធ្វើការដាក់លក់

សមាសភាគទី២

ជំនាញ និងសហគ្រិនភាព

- កម្មវិធីបណ្តុះបណ្តាលជំនាញ
- កម្មវិធីជំនួយហិរញ្ញវត្ថុខ្នាតតូច (ឬកម្មវិធីប្រកួតភាពច្នៃប្រឌិត)

សមាសភាគទី៣

វេទិការិនិយោគិន

- ការទទួលបានហិរញ្ញវត្ថុតាមរយៈអ្នកវិនិយោគិនមូលធន
- សមាគមពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកម្ពុជា
- ការបង្កើនសមត្ថភាពប្រតិបត្តិការរបស់ប្រៃសណីយ៍កម្ពុជាក្នុងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

លំហឌីជីថលនៅកម្ពុជា

(ប្រភព៖ Khmer Enterprise)

ទិដ្ឋភាពជារួមនៃបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា

(ប្រភព៖ Khmer Enterprise)

E-COMMERCE ECOSYSTEM & STATISTICS

THIRD EDITION

Please scan to download iTrade Bulletin

Go4eCAM Project

The 1st national e-commerce project, aiming to realize the benefit of Cambodian SMEs to participate in e-commerce sector.

CAMBODIATRADE

Establish a national B2B2C platform **CAMBODIA**TRADE (cambodiatrade.com)

Provide skills and entrepreneurship for e-commerce **(SME eBiZNest)**

Access to financing **(investor platform)**

Go4eCam's Tracks

Track I	Track II	Track III
CAMBODIATRADE - Officially launched on **31st March 2022** - Free-to-use platform for MSMEs to sell products in domestic and cross-border markets - Has onboarded more than 100 SMEs and more than 1000 products listed	SME eBizNest - Incubation programme - Small grant programme (innovation challenge)	Investor Platform - Accessing to finance through Venture Capitalist - E-commerce association - Operational readiness

Digital Landscape in Cambodia



(Source: Khmer Enterprise)

Overview of FinTech in Cambodia

Online Purchase
3.1% active users (2021)

Utilise Online Banking
5.9% active users (2022)

Utility Digital Payments
0.9% active users (2022)

Mobile Money Account
80% (2022)

Account at Financial Instutituion
36.5% (2022)
2.3M users aged under 30

Card Ownership
7.2% Debit Card (2022)
0.6% Credit Card (2022)

(Source: Khmer Enterprise)

ពីខែមករាដល់កក្កដា ការនាំចេញគ្រាប់ស្វាយចន្ទីមិនទាន់កែថ្នៃទៅវៀតណាមធ្លាក់ចុះប្រមាណ ៣៥% ខណៈភ្លៀងជោគជាំប៉ះពាល់ដល់គុណភាពនិងផ្ទៃដីដាំដុះ

ប្រភព៖ Phnom Penh Post

កម្ពុជា បាននាំចេញគ្រាប់ស្វាយចន្ទីមិនទាន់កែថ្នៃទៅវៀតណាមប្រមាណ ៦៦០.០០០ តោន ដែលមានតម្លៃជាង ១,០៨ពាន់លានដុល្លារ ក្នុងរយៈពេល៧ខែដំបូងនៃឆ្នាំ ២០២២ ដែលបានធ្លាក់ចុះចំនួន ៣៥០.០០០ តោន ឬ ៣៤,៦៥% នៃផលធៀបប្រចាំឆ្នាំ នេះបើយោងតាមលោក អួន ស៊ីឡុត ប្រធានសមាគមស្វាយចន្ទីកម្ពុជា។ ដោយសារកង្វះខាតបរិក្ខារកែថ្នៃគ្រាប់ស្វាយចន្ទីឱ្យត្រូវតាមស្តង់ដារអន្តរជាតិ គ្រាប់ស្វាយចន្ទីដែលប្រមូលផលបានពីកម្ពុជាត្រូវបាននាំចេញជាគ្រាប់ចន្ទីមិនទាន់កែថ្នៃប្រមាណ ៩៥% ទៅវៀតណាម និងប្រមាណ ២% ទៀតទៅឥណ្ឌា ក្រៅពីនោះត្រូវបានកែថ្នៃ ដើម្បីដាក់លក់លើទីផ្សារក្នុងស្រុកនិងទីផ្សារអន្តរជាតិ។ លោកបានបន្តថា តម្លៃលក់ដុំគ្រាប់ស្វាយចន្ទីមិនទាន់កែថ្នៃបច្ចុប្បន្នមានតម្លៃចាប់ពី ១.៣៥០ ទៅ ១.៧៥០ ដុល្លារអាម៉េរិកក្នុងមួយតោន អាស្រ័យលើគុណភាពនៃគ្រាប់ស្វាយចន្ទី។ គុណភាពនិងមាត្រដ្ឋានផ្សេងទៀតនៃដំណាំមានភាពខុសប្លែកគ្នាខ្លាំង អាស្រ័យលើលក្ខខណ្ឌអាកាសធាតុ។ លោកស្រី អិន ឡៃហួត ម្ចាស់សិប្បកម្មកែថ្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ដែលមានទីតាំងនៅខេត្តកំពង់ធំ បានប្រាប់ថា ការដាំដុះហាក់បីដូចជាមិនទទួលបានផល ជាទីគាប់ចិត្តទេ ប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយមូលហេតុខ្វះថវិកា ហើយមធ្យោបាយកែថ្នៃធំៗ ឱ្យស្របតាមស្តង់ដារទទួលស្គាល់នៅមានកម្រិត បើទោះជាមានការសោទរថាគ្រាប់ស្វាយចន្ទីកម្ពុជាមានគុណភាពខ្ពស់ និងរសជាតិល្អក៏ដោយ។ ចុចទីនេះដើម្បីអានបន្ថែម

ផ្សារពាណិជ្ជកម្មខេមបូឌាត្រេដកំពុងជួយលើកស្ទួយការលក់ផលិតផលរបស់សហគ្រាសធុនតូចនិងមធ្យម

ប្រភព៖ Phnom Penh Post

ក្រុមហ៊ុនយ៉ាងតិចចំនួន ១៣៥ បានចុះឈ្មោះលើថ្នាលផ្សារពាណិជ្ជកម្មខេមបូឌាត្រេដ (CambodiaTrade) ដែលជាទីផ្សារអនឡាញរបស់រដ្ឋ ដែលបានដាក់លក់ផលិតផលជាង ១.២០០ មុខសម្រាប់អតិថិជនទូទាំងពិភពលោកចាប់តាំងពីថ្នាលអនឡាញនេះត្រូវបានដាក់ឱ្យដំណើរការសាកល្បងកាលពីខែកញ្ញា ឆ្នាំ២០២១។ ទន្ទឹមនឹងទិន្នន័យខាងលើ លោកជំទាវ តឹកវ៉ែត កំរង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានជំរុញឱ្យសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកទាំងអស់ឱ្យចុះឈ្មោះជាមួយគេហទំព័រពាណិជ្ជកម្មខេមបូឌាត្រេដ ដើម្បីដាក់លក់ផលិតផលអនឡាញទៅកាន់ទីផ្សារពិភពលោក។ លោកជំទាវបានថ្លែងថា៖ "សហគ្រាសធុនតូចនិងមធ្យម ដែលកំពុងដាក់លក់ផលិតផលនៅលើគេហទំព័រ cambodiatrade.com បានត្រៀមខ្លួនរួចរាល់ក្នុងការទទួលការបញ្ជាទិញនិងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ជាមួយនិងការដឹកជញ្ជូនទាំងក្នុងនិងក្រៅស្រុក ក្នុងទម្រង់ធុរកិច្ច-ធុរកិច្ច និងទម្រង់ធុរកិច្ច-អតិថិជន"។ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្រសួងពាណិជ្ជកម្ម បានដាក់ឱ្យដំណើរការជាផ្លូវការនូវគេហទំព័រពាណិជ្ជកម្មខេមបូឌាត្រេដ ដែលជាទីផ្សារអនឡាញមួយក្នុងការប្រមូលផ្តុំទីផ្សារ និងត្រូវបានចាត់ទុកថា ជាធាតុផ្សំសំខាន់នៃគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (Go4eCAM)។ ចុចទីនេះដើម្បីអានបន្ថែម

វិបត្តិសេដ្ឋកិច្ចសកលប៉ះពាល់ដល់ការនាំចេញកៅស៊ូ

ប្រភព៖ Khmer Times

វិបត្តិសេដ្ឋកិច្ចសកល ការកើនឡើងអតិផរណា ការដំឡើងអត្រាការប្រាក់នៅអាម៉េរិក បញ្ហាសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ស្ថានភាពភូមិសាស្ត្រនយោបាយរវាងអាម៉េរិកនិងចិន និងការបិទខ្ទប់តំបន់ខ្លះនៃប្រទេសចិន បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការនាំចេញកៅស៊ូកម្ពុជា ក្នុងរយៈពេលប្រាំពីរខែដំបូងនៃឆ្នាំ២០២២ នេះបើតាមប្រសាសន៍របស់មន្ត្រីជាន់ខ្ពស់មួយរូប។ ប្រាក់ចំណូលរបស់កម្ពុជាដែលបានមកពីការនាំចេញកៅស៊ូសួតក្នុងរយៈពេល៧ខែដំបូងនៃឆ្នាំនេះ បានធ្លាក់ចុះ ៦% មកនៅត្រឹម ២៥៤,៨ លានដុល្លារអាម៉េរិក បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ របាយការណ៍របស់អគ្គនាយកដ្ឋានកៅស៊ូបានឱ្យដឹងថា កម្ពុជាបាននាំចេញកៅស៊ូសួតចំនួន ១៦១.៥៦២ តោន អំឡុងខែមករាដល់ខែកក្កដា ពោលគឺធ្លាក់ចុះ ០,៣% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១។ ចំពោះបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ដែលឧស្សាហកម្មកៅស៊ូកម្ពុជាកំពុងជួបប្រទះ លោកមានប្រសាសន៍ថា “ទីផ្សារកៅស៊ូមិនមានស្ថិរភាព ដោយសារយើងពឹងផ្អែកលើការនាំចេញ”។ ចុចទីនេះដើម្បីអានបន្ថែម

កសិករអាចស្វែងរកឥណទាន ដែលមានអត្រាការប្រាក់ទាប ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម បន្ទាប់ពីមានកិច្ចព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ប្រភព៖ The Phnom Penh Post

សហគមន៍កសិកម្ម អាចទទួលបានការកាត់បន្ថយថ្លៃដើមផលិតកម្ម តាមរយៈឥណទានការប្រាក់ទាប បន្ទាប់ពីមានកិច្ចព្រមព្រៀងឥណទានឧបត្ថម្ភធនរវាងធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម (គ្រប់គ្រងដោយរដ្ឋ) និងស្ថាប័នហិរញ្ញវត្ថុចំនួនបី។ កិច្ចព្រមព្រៀងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែសីហា ជាមួយធនាគារប្រៃសណីយ៍កម្ពុជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចម្រើន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ នៅក្រោមគម្រោងពិពិធកម្មវិស័យកសិកម្មកម្ពុជា។ កិច្ចព្រមព្រៀងនេះមានគោលបំណងលើកកម្ពស់វិស័យកសិកម្ម ដែលជាវិស័យឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា ឱ្យកាន់តែប្រសើរនៅក្នុងដំណាក់កាល ដែលពិភពលោកកំពុងជួបវិបត្តិស្បៀងអាហារ ។ ចុចទីនេះដើម្បីអានបន្ថែម

Jan-Jul Raw Cashew Exports to Vietnam Fall Nearly 35% as Rains Hit Quality, Yields

Source: Phnom Penh Post

In the first seven months of 2022, Cambodia exported about 660,000 tonnes of raw cashew nuts worth more than $1.08 billion to Vietnam, down by 350,000 tonnes or 34.65% year-on-year, according to the Cashew Nut Association of Cambodia president Uon Silot. Without much in the way of processing facilities that match international standards, about 95% of cashew nuts produced in Cambodia are exported raw to Vietnam, another 2% are shipped raw to India, and the rest are processed locally for domestic and international consumption. The wholesale going-rate for raw cashew nuts is currently from $1,350-1,750, depending on cashew quality. The quality and other parameters of the crop vary widely due to weather conditions, he said. In Lai Huot, owner of Chey Sambor Cashew Nut Processing Handicrafts based in Kampong Thom province, commented that cultivation has seemingly not gained the desired traction in recent years due to a lack of funds and limited number of large processing facilities which meet recognized standards, despite the acclaim that Cambodian cashew nuts have received for their quality and impeccable taste. Click here to read more

Cambodia Trade Gains SME Momentum

Source: The Phnom Penh Post

At least 135 companies registered with CambodiaTrade, a government-hosted online marketplace, have displayed more than 1,200 products on sale globally since the application's soft-launch last September. Secretary of Commerce Tek Reth Kamrong urged more local small- and medium-sized enterprises (SME) to register with CambodiaTrade to promote their products to domestic and foreign markets. "Those which have displayed their products on Cambodiatrade.com are well-prepared for business-to-business and business-to-customer orders and electronic payments, as well as domestic and international shipments," she said. On March 31, the Ministry officially launched CambodiaTrade with integrated marketing solutions, regarded as a key component of the Cambodia E-Commerce Development Project (Go4eCAM). Click here to read more

Global Economic Crisis Hurts Rubber Exports

Source: Khmer Times

Global economic crisis, rising inflation, interest rate hikes in the United States, the Russia-Ukraine war, the geopolitical situation involving US and China, and a partial shutdown in China adversely affected rubber exports from Cambodia in the first seven months of this year, a top official said. Cambodia's revenue from dry rubber exports in the first seven months of this year dropped 6% to $254.8 million compared to the same period in the previous year. According to a General Directorate of Rubber report, the country exported 161,562 tones of dry rubber in the January-July period, a decrease of 0.3% compared with the same period in 2021. On the current challenges being faced by the rubber industry in the country, he said, "The rubber market is unstable because we rely on exports". Click here to read more

Farmers Can Seek Low-Interest Loans to Trim Production Costs after ARDB Deal

Source: Phnom Penh Post

Agricultural communities can look towards reducing production costs via low-interest loans following a subsidiary loan agreement between state-owned Agricultural and Rural Development Bank (ARDB) and three financial institutions. The agreement was signed with one commercial bank and two microfinance institutions (MFI) – Cambodia Post Bank Plc, Chamroeun Microfinance Plc and AMK Microfinance Institution Plc – under the Cambodia Agricultural Sector Diversification Project (CASDP) on August 15. The agreement is aimed at propping up the agricultural sector, a mainstay of the Cambodian economy, at a time when the world is facing a food crisis. Click here to read more

អាម៉េរិកប្រាប់ឥណ្ឌាថាកប៉ាល់ឥណ្ឌាត្រូវបានប្រើប្រាស់ដើម្បីដឹកប្រេងឥន្ធនៈរុស្ស៊ីទៅញូវយ៉ក

ប្រភព៖ Reuters

សហរដ្ឋអាម៉េរិក បានបង្ហាញការព្រួយបារម្ភចំពោះឥណ្ឌា ដែលកាលពីដើមឆ្នាំនេះ ប្រទេសឥណ្ឌាត្រូវបានរុស្ស៊ីប្រើប្រាស់ ដើម្បីដឹកជញ្ជូនប្រេងឥន្ធនៈដែលផលិតចេញពីប្រេងឆៅរុស្ស៊ី ទៅកាន់ទីក្រុងញូវយ៉ក តាមរយៈការផ្ទេរនៅសមុទ្រអន្តរជាតិ នេះបើយោងតាមសម្តីមន្ត្រីជាន់ខ្ពស់ធនាគារកណ្តាលឥណ្ឌាមួយរូប។ ទណ្ឌកម្មរបស់អាម៉េរិកលើរុស្ស៊ីចំពោះការឈ្លានពានអ៊ុយក្រែនកាលពីខែកុម្ភៈ គឺហាមឃាត់ការនាំចូលផលិតផលថាមពល ដែលមានដើមកំណើតនៅរុស្ស៊ី រួមមានប្រេងឆៅ ឥន្ធនៈចម្រាញ់រួច ធ្យូងថ្ម និងឧស្ម័ន។ លោក ម៉ៃឃើល ប្រាតា ទេសាភិបាលរងធនាគារកណ្តាលឥណ្ឌា បាននិយាយថា “រឿងកើតឡើងបែបនេះ កប៉ាល់ឥណ្ឌាបានបើកទៅជួបកប៉ាល់ដឹកប្រេងរុស្ស៊ី និងផ្ទេរប្រេងចេញនៅកណ្តាលសមុទ្រ រួចពួកគេបើកទៅកំពង់ផែមួយនៅរដ្ឋគូចារ៉ាត។ ប្រេងទាំងនោះត្រូវបានចម្រាញ់ជាសារធាតុសម្រាប់ផលិតប្លាស្ទិក”។ លោក ប្រាតា មិនបានបង្ហាញឈ្មោះ ឬទិន្នន័យពីកប៉ាល់នោះទេ និងបានបន្ថែមថា “សារធាតុដែលចម្រាញ់រួចនោះ ត្រូវបានរក្សាទុកលើកប៉ាល់ដដែល និងបើកចេញទៅដោយគ្មានទិសដៅ។ រហូតដល់កណ្តាលសមុទ្រ ទើបកប៉ាល់ទទួលបានទិសដៅ និងបង្វែរទៅញូវយ៉ក”។ ឥណ្ឌាគឺជាប្រទេសនាំចូល និងប្រើប្រាស់ប្រេងធំលំដាប់ទីបីនៅលើពិភពលោក និងបានក្លាយជាប្រទេសធំមួយក្នុងការនាំចូលប្រេងពីរុស្ស៊ីតាំងពីរុស្ស៊ីឈ្លានពានអ៊ុយក្រែនមក ដែលពីមុនមកឥណ្ឌានាំចូលតិចតួចប៉ុណ្ណោះពីរុស្ស៊ី។ ចុចទីនេះដើម្បីអានបន្ថែម

ការនាំចូលថាមពលក្នុងតម្លៃថ្លៃ បណ្តាលឱ្យតំបន់ចាយប្រាក់អឺរ៉ូជួបវិនិភាពពាណិជ្ជកម្មក្នុងខែមិថុនា

ប្រភព៖ Reuters

យោងតាមទិន្នន័យពីអឺរ៉ូស្តេត ប្រទេសចាយប្រាក់អឺរ៉ូបានជួបវិនិភាពពាណិជ្ជកម្មក្នុងខែមិថុនា បន្ទាប់ពីសម្រេចបានអតិរេកពាណិជ្ជកម្មកាលពីឆ្នាំមុន ដោយសារតែតម្លៃឧស្ម័ននិងប្រេងនាំចូលកើនឡើង។ យោងទិន្នន័យបណ្តោះអាសន្ន ទំហំវិនិភាពពាណិជ្ជកម្មរវាងប្រទេសចាយប្រាក់អឺរ៉ូជាមួយប្រទេសដទៃទៀត មានចំនួន ២៤,៦ ប៊ីលានអឺរ៉ូ ក្នុងខែមិថុនាធៀបនឹងអតិរេក ១៧,២ ប៊ីលានអឺរ៉ូ កាលពីឆ្នាំ ២០២១។ តែបើយោងតាមទិន្នន័យផ្លូវការ ទំហំវិនិភាពកើនឡើងពី ២៧,២ ប៊ីលានអឺរ៉ូ ក្នុងខែឧសភា ដល់ ៣០,៨ ប៊ីលានអឺរ៉ូ ក្នុងខែមិថុនា។ អឺរ៉ូស្តេតមិនបានផ្តល់ទិន្នន័យលម្អិតនីមួយៗ ពីវិនិភាពពាណិជ្ជកម្មសម្រាប់តំបន់ចាយប្រាក់អឺរ៉ូទេ ប៉ុន្តែសម្រាប់សហភាពអឺរ៉ុប វិនិភាពថាមពលក្នុង៦ខែឆ្នាំនេះ កើនជិតបីដង ពី ១០៥,៦ ប៊ីលានអឺរ៉ូ ក្នុងឆ្នាំ ២០២១ ទៅ ២៩០,៨ ប៊ីលានអឺរ៉ូ ក្នុងឆ្នាំនេះ។ វិនិភាពពាណិជ្ជកម្មរវាងសហភាពអឺរ៉ុបនិងរុស្ស៊ី ដែលជាប្រទេសផ្គត់ផ្គង់ប្រេង និងឧស្ម័នដ៏សំខាន់ កើនជិតបួនដង ពី ២៤,៦ ប៊ីលានអឺរ៉ូ ដល់ ៩០,៦ ប៊ីលានអឺរ៉ូ ក្នុងរយៈពេល៦ខែដូចគ្នាធៀបនឹងឆ្នាំមុន។ វិនិភាពពាណិជ្ជកម្មរវាងសហភាពអឺរ៉ុបជាមួយប្រទេសន័រវែស ដែលជាប្រទេសអាចជំនួសរុស្ស៊ីផ្នែកខ្លះក្នុងការនាំចូលទៅអឺរ៉ុប ក៏កើនឡើងខ្លាំងដែរពី ០,៥ ប៊ីលានអឺរ៉ូ ដល់ ៣៥,៨ ប៊ីលានអឺរ៉ូ ធៀបនឹងឆ្នាំមុន។ ការនាំចូលរបស់សហភាពអឺរ៉ុបពីចិនក៏កើនឡើងផងដែរ បន្ទាប់ពីការបិទខ្ទប់ដែលបណ្តាលមកពីវិបត្តិកូវីដកាលពីឆ្នាំ២០២១ ខណៈដែលការនាំចេញទៅចិនធ្លាក់ចុះនាំឱ្យវិនិភាពពាណិជ្ជកម្ម កើនឡើងពី ៩៨ ប៊ីលានអឺរ៉ូ ដល់ ១៨៩,៥ ប៊ីលានអឺរ៉ូ ធៀបនឹងឆ្នាំមុន។ ចុចទីនេះដើម្បីអានបន្ថែម

ការផ្តោតរបស់ប្រទេសចិនលើបច្ចេកវិទ្យា ៥G អនុញ្ញាតឱ្យមានបរិវត្តកម្មឌីជីថលយ៉ាងទូលំទូលាយ

ប្រភព៖ Xinhua

ប្រទេសចិន បាននិងកំពុងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ៥G របស់ខ្លួនក្នុងល្បឿនយ៉ាងលឿន ដោយប្រើប្រាស់បច្ចេកវិទ្យាឥតខ្សែជំនាន់ចុងក្រោយ ដើម្បីជួយសម្រួលដល់ការធ្វើឌីជីថលការបូនីយកម្មនៃវិស័យផ្សេងៗគ្នាក្នុងប្រទេស។ ត្រឹមដំណាច់ខែមិថុនា ស្ថានីយមូលដ្ឋាន ៥G ចំនួនប្រមាណ ១,៨៥ លាន ត្រូវបានសាងសង់ឡើង ដោយបានផ្តល់សេវាដល់អ្នក

ប្រើប្រាស់ជាង ៤៥០ លាននាក់ ដែលចំនួនទាំងនេះស្មើជាង ៦០% នៃចំនួនស្ថានីយនិងអ្នកប្រើប្រាស់សរុបទូទាំងពិភពលោក។ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបណ្តាញទូរគមនាគមន៍ ដែលមានល្បឿនលឿន ភាពជឿជាក់ខ្ពស់ និងភាពរាំងស្ទះតិចតួច បាននិងកំពុងជួយជំរុញឱ្យមានការអភិវឌ្ឍវិស័យមួយចំនួននាពេលអនាគត មានដូចជា រោងចក្រឆ្លាតវៃ សេវាវេជ្ជសាស្ត្រ (ការវះកាត់ពីចម្ងាយ) និងកសិដ្ឋានឌីជីថល។ ចុចទីនេះដើម្បីអានបន្តែម

ការរឹតត្បិតប្រព័ន្ធឌីជីថល ជំរុញឱ្យមានឧបសគ្គពាណិជ្ជកម្ម និងបំបែកអ៊ីនធឺណិតសកល

ប្រភព៖ DIGITAL TRADE

ការពង្រីកការរឹតត្បិតលើការបញ្ចេញមតិដោយសេរី និងការចូលប្រើប្រាស់ព័ត៌មានទៅក្នុងវិស័យឌីជីថល បន្តកើនឡើងជាសកល ដែលធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ ត្រឹមតែមួយឆ្នាំមុន រុស្ស៊ី បានផ្តាច់ខ្លួនជាផ្លូវការពីប្រព័ន្ធអ៊ីនធឺណិតសកល និងបានបង្កើនការបង្ក្រាបលើការផ្សព្វផ្សាយព័ត៌មាន និងមតិរិះគន់រដ្ឋាភិបាល និងការឈ្លានពានអ៊ុយក្រែន។ ទិន្នន័យមួយបានបង្ហាញថា ការរឹតត្បិតតាមប្រព័ន្ធឌីជីថល បានបង្កគ្រោះថ្នាក់ដល់ផលប្រយោជន៍សេដ្ឋកិច្ចរបស់អាម៉េរិក។ របាយការណ៍ថ្មីមួយពីគណៈកម្មការពាណិជ្ជកម្មអន្តរជាតិរបស់អាម៉េរិក (USITC) បានបង្ហាញថា ការរឹតត្បិតប្រព័ន្ធឌីជីថលទាំងឡាយ ដោយរដ្ឋាភិបាលនៃប្រទេសណាមួយ មិនថាជាការទប់ស្កាត់ឬបិទសេវាកម្មអ៊ីនធឺណិត ការបិទអ៊ីនធឺណិតទាំងស្រុង ឬរារាំងមិនឱ្យក្រុមហ៊ុនបរទេសផ្តល់សេវាអ៊ីនធឺណិតនៅក្នុងទីផ្សារនោះ អាចបង្កផលប៉ះពាល់ដល់ក្រុមហ៊ុន ដែលកំពុងប្រតិបត្តិការ នៅក្នុងទីផ្សារប្រទេសទាំងនោះ។ ការមិនអនុញ្ញាតឱ្យសេវាកម្មអ៊ីនធឺណិតចូលក្នុងទីផ្សារទាំងស្រុង នឹងអាចបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការនាំចេញសេវាកម្មឌីជីថល។ គណៈកម្មការនេះ ក៏បានប៉ាន់ប្រមាណថា បណ្តាញសង្គម និងក្រុមហ៊ុនផ្តល់សេវាបង្កើតវីដេអូដោយអ្នកប្រើប្រាស់ បានខាតបង់យ៉ាងហោចណាស់រាប់រយលាន និងអាចឈានដល់រាប់សិបប៊ីលានដុល្លារអាម៉េរិក ដោយសារការរឹតត្បិតច្រកទីផ្សារ សម្រាប់សេវាកម្មឌីជីថលក្នុងប្រទេសចិនតាមរយៈការអនុវត្តគោលនយោបាយ "Great Firewall of China"។ ចុចទីនេះដើម្បីអានបន្តែម

អតិផរណានិងហិរញ្ញវត្ថុខ្សែចង្វាក់ផ្គត់ផ្គង់៖ ការគ្រប់គ្រងឧបសគ្គកើតឡើងនៅខាងមុខ

ប្រភព៖ Global Trade Review

ការរំខានពីជំងឺរាតត្បាតកូវីដ-១៩ ដល់ទាំងសេដ្ឋកិច្ចនិងខ្សែចង្វាក់ផ្គត់ផ្គង់សកល រួមជាមួយនឹងការកើនឡើងខ្ពស់នៃថ្លៃទំនិញ និងភាពមិនច្បាស់លាស់បណ្តាលមកពីការឈ្លានពានរបស់រុស្ស៊ីលើអ៊ុយក្រែន បានធ្វើឱ្យអតិផរណាក្លាយជាក្តីព្រួយបារម្ភសារជាថ្មីរបស់ពិភពលោក។ ស្របពេលដែលសេដ្ឋកិច្ចពិភពលោកបានបើកឡើងវិញ កំណើនតម្រូវការនិងឥទ្ធិពលរំពា (Bullwhip Effect) បានធ្វើឱ្យបណ្តាញចែកចាយកើនលើសលប់ ដែលបង្កឱ្យមានកំណើននៃចំណាយខណៈពេលដែលសង្គ្រាមនៅអ៊ុយក្រែន បានធ្វើឱ្យថ្លៃថាមពលនិងអាហារកើនឡើង។ ទាំងនេះជាបញ្ហាប្រឈម ដែលពិភពលោកមិនដែលជួបប្រទះក្នុងសម័យទំនើប។ ក្តីបារម្ភទាំងនេះកើតឡើង ស្របពេលដែលអតិផរណានៅអាម៉េរិកបានឡើងដល់ ៨,៦% ក្នុងខែឧសភា ដែលជាកម្រិតខ្ពស់បំផុតចាប់តាំងពីឆ្នាំ១៩៨១។ អតិផរណានៅចក្រភពអង់គ្លេស បានឈានដល់ ៩% ដែលជាកម្រិតខ្ពស់បំផុតចាប់តាំងពីឆ្នាំ១៩៨២ ខណៈដែលកម្រិតនេះកើនដល់ ៨,១% នៅក្នុងតំបន់ចាយប្រាក់អឺរ៉ូ។ កាលៈទេសៈដ៏លំបាកទាំងនេះទាមទារឱ្យមាន ការឆ្លើយតបប្រកបដោយភាពច្នៃប្រឌិតពីទីផ្សារ នៅពេលដែលអ្នកពាក់ព័ន្ធព្យាយាមគ្រប់គ្រងអតិផរណា ដែលកើតចេញពីកំណើនថ្លៃចំណាយ។ ចុចទីនេះដើម្បីអានបន្តែម

ជប៉ុន កូរ៉េខាងត្បូង និងកោះតៃវ៉ាន់ ទិញប្រេងឥន្ធនៈពីរុស្ស៊ីប្រមាណ ៥,៥ ប៊ីលានដុល្លារអាម៉េរិក

ប្រភព៖ Nikkei Asia

ទិន្នន័យរបស់មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវថាមពលនិងខ្យល់ស្អាត (Center for Research on Energy and Clean Air—CREA) បានបង្ហាញថា ជប៉ុន កូរ៉េខាងត្បូង និងកោះតៃវ៉ាន់ បាននាំចូលប្រេងឥន្ធនៈផូស៊ីលពីរុស្ស៊ីសរុបប្រមាណ ៥,៥ ប៊ីលានដុល្លារអាម៉េរិក ក្នុងរយៈពេល ៥ ខែបន្ទាប់ពីរុស្ស៊ីឈ្លានពានអ៊ុយក្រែន ដែលនេះបង្ហាញពីការនៅតែបន្តពឹងផ្អែកលើទំនិញរុស្ស៊ីពីសំណាក់សេដ្ឋកិច្ចទាំងបីនេះ បើទោះបីជាប្រទេសផ្សេងផ្តាច់ទំនាក់ទំនងធុរកិច្ចជាមួយរុស្ស៊ីក៏ដោយ។ យោងតាមការប៉ាន់ស្មានរបស់មជ្ឈមណ្ឌល CREA ជប៉ុនបានទិញឆ្សងឋ ប្រេង និងឧស្ម័ន ពីរុស្ស៊ីប្រមាណ ២,៦ ប៊ីលានដុល្លារអាម៉េរិក ចន្លោះថ្ងៃទី២៤ ខែកុម្ភៈ (ថ្ងៃដែលរុស្ស៊ីឈ្លានពានអ៊ុយក្រែន) និងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២២ ខណៈកូរ៉េខាងត្បូងបានទិញប្រមាណ ១,៧ ប៊ីលានដុល្លារអាម៉េរិក និងកោះតៃវ៉ាន់បានទិញប្រមាណ ១,២ ប៊ីលានដុល្លារអាម៉េរិក។ ព័ត៌មាននេះកើតឡើងបន្ទាប់ពី ជប៉ុន កូរ៉េខាងត្បូង និងកោះតៃវ៉ាន់ បង្ហាញការគាំទ្ររបស់ខ្លួនចំពោះអ៊ុយក្រែន តែពុំបានបង្ហាញពីកាលបរិច្ឆេទជាក់លាក់ចំពោះការបញ្ឈប់ទិញប្រេងឥន្ធនៈពីរុស្ស៊ីនោះទេ ខណៈប្រទេសសម្ព័ន្ធមិត្តអឺរ៉ុបរបស់ខ្លួន បានដាក់ទណ្ឌកម្មលើរុស្ស៊ីដើម្បីបញ្ចប់ការនាំចូលឆ្សងឋនិងប្រេងឥន្ធនៈពីរុស្ស៊ីនាចុងឆ្នាំនេះ។ របាយការណ៍របស់មជ្ឈមណ្ឌល CREA ក៏បានបង្ហាញផងដែរថា ការបញ្ជាទិញពីសេដ្ឋកិច្ចទាំងបីនេះ បានផ្តល់ចំណូលដល់ថវិកាជាតិរុស្ស៊ីប្រមាណ ១ ប៊ីលានដុល្លារអាម៉េរិក ក្នុងរយៈពេល៥ខែក្រោយការឈ្លានពានអ៊ុយក្រែន ហើយសេដ្ឋកិច្ចនៅតំបន់អាស៊ីបូព៌ាទាំងនេះ អាចក្លាយជាអ្នកនាំចូលប្រេងឥន្ធនៈពីរុស្ស៊ីដ៏សំខាន់ស្របពេលដែលប្រទេសផ្សេងទៀតបានដាក់ទណ្ឌកម្មលើរុស្ស៊ី។ ចុចទីនេះដើម្បីអានបន្ថែម

US Tells India that Indian Ship Used to Reroute Russian-Linked Fuel to New York

Source: Reuters

The United States has expressed concern to India that it was used earlier this year to export fuel made from Russian crude to New York through high-seas transfers, a top Indian central banker said. U.S. sanctions on Russia for its February invasion of Ukraine prohibit imports to the United States of Russian-origin energy products including crude oil, refined fuels, distillates, coal, and gas. "It turns out, an Indian ship met a Russian tanker in mid-seas, picked up oil in the mid-seas, came to a port in Gujarat, it was processed in that port and converted into a distillate which actually goes into making single-use plastic," said Reserve Bank of India Deputy Governor, Michael Patra. "The refined output was put back on that ship and it set sail without a destination. In the mid-seas it received the destination, so it reached its course, went to New York. " Patra did not name the ship or give any other details. India, the world's third-biggest oil importer and consumer, has become one of the biggest importers of Russian oil since the invasion of Ukraine, having bought very little of it previously. Click here to read more

Costly Energy Imports Push Euro Zone into Trade Deficit in June

Source: Reuters

Euro zone countries swung into a trade deficit in June from a surplus 12 months earlier because of soaring prices of imported gas and oil, Eurostat data showed on Tuesday. Eurostat said the trade gap of the 19 countries sharing the euro with the rest of the world, unadjusted for seasonal swings, was 24.6 billion euros in June, compared to a 17.2 billion surplus in June 2021. Seasonally adjusted, the deficit was even bigger at 30.8 billion widening from 27.2 billion in May. Eurostat did not give a breakdown for the euro zone, but for the whole European Union the trade deficit in energy for the first six months of the year almost tripled to 290.8 billion euros from 105.6 billion in the same period of 2021. The EU's trade gap with Russia, its main supplier of gas and oil, almost quadrupled to 90.6 billion euros in the first six months from 24.6 billion in the same period of last year. The EU's trade gap with Norway, which the bloc sees as a partial replacement for imports from Russia, surged even more spectacularly to 35.8 billion euros in the first six months from only 0.5 billion the year before. Also, the EU's imports from China surged after COVID pandemic lockdowns have curbed them in 2021, while exports to China fell, producing a trade gap of 189.5 billion euros in the first six months compared to 98.0 billion a year earlier. Click here to read more

China Focus: 5G Tech Enables Comprehensive Digital Transformation

Source: Xinhua

China has been expanding its 5G infrastructure at a rapid pace, utilizing the next-generation wireless technology to facilitate the digitalization of different sectors of the country. By the end of June, some 1.85 million 5G base stations have been built,supporting over 450 million end users, both accounting for over 60 percent of the global total. The rapidly expanding telecom network, featuring high speed, high reliability and low latency, has enabled futuristic scenarios in sectors like smart factory, medical services (remote surgery) and digital farm. Click here to read more

Digital Censorship Drives Trade Barriers, Fragments the Global Internet

Source: DIGITAL TRADE

Efforts to extend restrictions on free expression and information access to the digital sphere continue to accelerate globally, with deeply damaging implications. Just in the past year, Russia has become effectively isolated from the global internet and increased crack downs on the dissemination of any news and opinion critical of the government and its invasion of Ukraine. Quantitative data showcasing the harm digital censorship imposed on U.S. economic interests has emerged. A new report from the U.S. International Trade Commission (USITC) sheds light on the economic toll that government-sponsored restrictions—whether from blocking or throttling services, shutting down the internet entirely, or barring foreign providers from the market—can have on companies operating in those markets. Outright exclusion from a market can prompt even more grave outcomes for digital exports. The USITC estimated that U.S. social media and user-generated video services providers lost at least hundreds of millions and potentially tens of billions of dollars as a result of restrictions to market access in the country resulting

from the censorship imposed by the "Great Firewall of China." Click here to read more

Inflation And Supply Chain Finance: Managing the Choppy Waters Ahead

Source: Global Trade Review

The Covid-19 pandemic's dramatic disruptions to both the global economy and the supply chains that keep it moving, along with the huge rise in commodity prices and overall uncertainty caused by Russia's invasion of Ukraine, have restored inflation's place at the top of concerns worldwide. *S*oaring demand and the bullwhip effect as the world re-opened has overwhelmed distribution networks, triggering a surge in costs, while the war in Ukraine has caused the prices of energy and food to skyrocket. These represent a challenge that is almost without precedent in modern times. These concerns have been borne out, with inflation in the US in May reaching 8.6%, its highest since 1981. In the UK, it reached 9%, its highest since 1982, while in the eurozone it reached a new peak of 8.1%. These challenging circumstances will require creative responses from the market as participants attempt to control rampant cost-push inflation in the wake of a generation where it was thought to be largely tamed. Click here to read more

Japan, South Korea, and Taiwan Buy US$5.5 Billion of Russian Fuel

Source: Nikkei Asia

Japan, South Korea, and Taiwan imported a combined $5.5 billion of fossil fuels from Russia in the five months following the invasion of Ukraine, according to the Center for Research on Energy and Clean Air (CREA), underscoring their ongoing reliance on commodities from the nation even as other countries sever business ties with it. The CREA estimates Japan brought in $2.6 billion of Russian coal, oil and gas between February 24—the date Russia invaded Ukraine—and July 31. Its estimate stood at $1.7 billion for South Korea and $1.2 billion for Taiwan. That comes as the three democracies express support for Ukraine without laying out concrete timelines for phasing out purchases of Russian fossil fuels, while many of their European peers have ratcheted up sanctions on Moscow, aiming to snuff out most coal and oil imports by year-end. Buying from the three countries contributed around $1 billion to Russia's federal budget over the five-month period, the center said in a report, adding that the East Asia economies could become top importers from Russia as sanctions kick in elsewhere. Click here to read more

ខណៈអវត្តមាននៃច្បាប់ជាសកល តាពស្របច្បាប់នៃយន្តការប្រឆាំងនឹងការគេចពន្ធឧបាស្រ័យនៅតែជាសំណួរ

លោក សុខ ប៊ុនថន
អនុប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ

លោក ជិនកេត តុលា
អនុប្រធានការិយាល័យនៃវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ

ស្ថាប័នសំខាន់ដែលមានចំណុចខ្វះខាត

អង្គការពាណិជ្ជកម្មពិភពលោក (WTO) ពិសេសស្ថាប័នដោះស្រាយវិវាទ (DSB) ដែលត្រូវបានគេប្រសិទ្ធនាមថាជាដើងឯកខាងលើកកម្ពស់យុត្តិធម៌ពាណិជ្ជកម្ម ឬ "Jewel in the Crown" នៅតែមិនអាចសម្រេចបាននូវយុត្តិធម៌ប្រកបដោយបរិយាប័ន្ធដោយសារតែការបន្តកើតមាននូវទិដ្ឋភាពចំនួនពីរលើច្បាប់របស់ខ្លួន៖ និយ័តកម្មនិយមជ្រុលនៅក្នុងប្រព័ន្ធច្បាប់ដែលមានស្រាប់របស់ខ្លួន និងការឆ្លើយតបយឺតយ៉ាវផ្នែកច្បាប់ទៅនឹងបញ្ហាប្រឈមដែលកើតមានថ្មីៗ។ ភាពខ្វះខាតផ្នែកច្បាប់ និងគោលនយោបាយទាំងនេះបណ្តាលឱ្យភាពលេចធ្លោនៃស្ថាប័ននេះ ក្លាយជាប្រធានបទដ៏សំខាន់ក្នុងការវែកញែកដេញដោលនាពេលកន្លងមកនេះ។

អ្វីដែលសំខាន់ បើទោះជាមានការសោទរចំពោះសមិទ្ធផលផ្នែកច្បាប់ ដែលអង្គការ WTO សម្រេចបាននាពេលថ្មីៗនេះ ពិសេសកិច្ចព្រមព្រៀងចំនួនពីរ (កិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម (TFA) ឆ្នាំ២០១៧ និងកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនលើវិស័យជលផល ឆ្នាំ២០២២) ក៏ស្ថាប័ននេះនៅតែបរាជ័យនៅក្នុងផ្នែកផ្សេងទៀត ដែលក្នុងនោះរួមមានអវត្តមាននៃច្បាប់ដែលមានអនុភាពគតិយុត្តពេញលេញពាក់ព័ន្ធនឹង "យន្តការប្រឆាំងនឹងការគេចពន្ធឧបាស្រ័យ" ទាំងដែលបញ្ហានេះត្រូវបានលើកមកពិភាក្សាយ៉ាងស្វិតស្វាញជាច្រើនទសវត្សរ៍មកហើយចាប់តាំងពីកិច្ចប្រជុំនៅជុំ Uruguay Round មកម្ល៉េះ។

បច្ចុប្បន្នភាពនៃការកំណត់និយមន័យ និងវិសាលភាពនៃការគេចពន្ធឧបាស្រ័យ

យន្តការប្រឆាំងការគេចពន្ធឧបាស្រ័យ មិនទាន់ទទួលបាននិយមន័យផ្លូវច្បាប់ដែលទទួលស្គាល់ជាសកលនៅឡើយទេ ប៉ុន្តែការដាក់វិធានការបែបនេះមានការកើនឡើង ជាពិសេសនៅអាម៉េរិក សហភាពអឺរ៉ុប (EU) និងសូម្បីប្រទេសវៀតណាម និងបណ្តាប្រទេសមួយចំនួនទៀត។ ប្រទេសទាំងនេះ រួមទាំង អូស្ត្រាលី នូវែលសេឡង់ អាហ្សង់ទីន ប្រេស៊ីល ឥណ្ឌា អាហ្វ្រិកខាងត្បូង និងតួកគី មានច្បាប់ក្នុងស្រុក ឬបទប្បញ្ញត្តិពាក់ព័ន្ធយន្តការប្រឆាំងការគេចពន្ធឧបាស្រ័យ។

ជាការពិត "ការគេចពន្ធឧបាស្រ័យ" មានអត្ថន័យស្រដៀងគ្នាទៅនឹង "ការគេចពន្ធ" ប៉ុន្តែវាក្យសព្ទទាំងពីរនេះមានលក្ខណៈបច្ចេកទេសខុសគ្នាត្រង់ថា "ការគេចពន្ធឧបាស្រ័យ" កើតចេញពីយន្តការឧបាស្រ័យពាណិជ្ជកម្ម (ប្រឆាំងការលក់បង្ហូចថ្លៃ ប្រឆាំងការផ្តល់ឧបត្ថម្ភធន ឬយន្តការគាំពារដោយដើម) រីឯ"ការគេចពន្ធ" កើតចេញពីបញ្ហានៃវិធានដើមកំណើតទំនិញ ដូចជាករណីដែលប្រទេសមួយ (ភាគី A) បានគេចវេសមិនបង់ពន្ធ MFN ដែលដាក់ដោយប្រទេសនាំចូល (ភាគី B) តាមរយៈការប្រើប្រាស់ប្រទេសទី៣ (ភាគី C) ជាច្រកនាំចេញទំនិញរបស់ខ្លួនទៅកាន់ប្រទេសនាំចូលនោះ (ភាគី B) ក្រោមប្រព័ន្ធអនុគ្រោះពន្ធដារដើម។ នៅក្នុងករណីប្រទេសចិន ការដាក់វិធានការលើការនាំចូលគ្រឿងបន្លាស់រថយន្ត ឆ្នាំ២០០៨ តំណាងភាគីចិនបានអះអាងថា វិធានការរបស់ខ្លួនប្រឆាំងការគេចវេសពីអត្រាពន្ធ MFN ក្រោមតារាងពន្ធគយរបស់ចិន ជាវិធានការប្រឆាំងនឹងការគេចពន្ធឧបាស្រ័យ។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះបានកំណត់ថា មកទល់ពេលនេះ មិនមានកស្តុតាង ឬឯកសារផ្លូវការណាមួយដែលអះអាងពីការ

ទទួលស្គាល់ ឬការពិភាក្សាណាមួយ ថាយន្តការប្រឆាំងការគេចពន្ធឧបាស្រ័យ ធ្លាប់ត្រូវបានធ្វើឡើងនៅក្នុងបរិបទនៃការគេចពន្ធគយធម្មតា ឬការបកស្រាយអំពីសម្បទានទាក់ទងនឹងពន្ធនាំចូលរបស់សមាជិកក្នុងវិសាលភាពនៃមាត្រា II នៃកិច្ចព្រមព្រៀង GATT ឆ្នាំ១៩៩៤។

កន្លងមក ការគេចពន្ធឧបាស្រ័យត្រូវបានប្រើដើម្បីប្រឆាំងនឹងការលក់បង្ហូចថ្លៃតែប៉ុណ្ណោះ ប៉ុន្តែអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) បានពង្រីកវិសាលភាពនៃយន្តការនេះ ដែលគ្របដណ្តប់ដល់សកម្មភាពគេចពីកាតព្វកិច្ចពន្ធផ្សេងៗទៀត ដែលប្រទេសសមាជិកបានប្តេជ្ញាអនុវត្តនៅក្រោមក្របខ័ណ្ឌ WTO រាប់បញ្ចូលទាំងការឧបត្ថម្ភធនលើការនាំចេញកសិផល កាតព្វកិច្ចគាំពារប្រឆាំងតបត និងការដាក់កំហិតលើបរិមាណនៃការនាំចេញ ជាដើម។ ទោះជាយ៉ាងណា យន្តការប្រឆាំងការគេចពន្ធលក់បង្ហូចថ្លៃ គឺជាឧបករណ៍គោលនយោបាយដ៏ពេញនិយម ដែលទាមទារការពិភាក្សាបន្ថែមទៀត។

ជាបច្ចេកទេស មានវិធីសាស្ត្រចំនួនបួន ដែលប្រទេសសមាជិកអង្គការ WTO អាចអនុវត្តដើម្បីគេចចេញផុតពីកាតព្វកិច្ចពន្ធប្រឆាំងការលក់បង្ហូចថ្លៃ។ វិធីសាស្ត្រទី១ គឺការគេចពន្ធឧបាស្រ័យដោយប្រើប្រាស់ប្រទេសទីបី (ឧ. ប្រទេស A ប្រើប្រាស់ប្រទេស B ជាច្រកនាំទំនិញចេញទៅប្រទេស C ដែលប្រទេស C បានដាក់ពន្ធប្រឆាំងនឹងការលក់បង្ហូចថ្លៃលើប្រទេស A)។ វិធីសាស្ត្រទី២ គឺការគេចពន្ធឧបាស្រ័យតាមរយៈប្រទេសនាំចូល (ឧ. ប្រទេស B បានដាក់ពន្ធប្រឆាំងការលក់បង្ហូចថ្លៃ លើប្រទេស A ដូច្នេះប្រទេស A នាំចេញតែផ្នែក ឬសមាសធាតុនៃផលិតផលដែលលក់បង្ហូចថ្លៃទៅប្រទេស B ដំឡើងក្នុងប្រទេស B ហើយលក់នៅទីនោះ)។ វិធីសាស្ត្រទី៣ គឺការគេចពន្ធឧបាស្រ័យតាមរយៈការផ្ទេរផលិតកម្ម (ឧ. ប្រទេស A បានផ្លាស់មូលដ្ឋានផលិតនៃផលិតផលលក់បង្ហូចថ្លៃ ទៅប្រទេស B ឬប្រទេសទីបី ដើម្បីផ្លាស់ប្តូរទីតាំងផលិត សំដៅគេចពីកាតព្វកិច្ចបង់ពន្ធលក់បង្ហូចថ្លៃដែលប្រទេស B បានដាក់។ វិធីសាស្ត្រទី៤ គឺការគេចពន្ធឧបាស្រ័យដោយផ្លាស់ប្តូរតែបន្តិចបន្តួចលើសណ្ឋាននៃផលិតផល (ឧ. ការផ្លាស់ប្តូរសណ្ឋានបន្តិចបន្តួចនៃផលិតផលលក់បង្ហូចថ្លៃ ដើម្បីបង្កើតឱ្យមានភាពខុសគ្នាតែបន្តិចលើទំនិញសម្រាប់នាំចេញទៅប្រទេស B)។

យន្តការប្រឆាំងការគេចពន្ធឧបាស្រ័យ៖ បញ្ហាចាស់ ក្នុងស្ថាប័នចាស់ គួរធ្វើកំណែទម្រង់ក្នុងបរិបទថ្មី?

ជាការពិតណាស់ ប្រទេសមួយចំនួន រួមទាំងអាម៉េរិកផងដែរ បានព្យាយាមជំរុញការធ្វើនិយ័តកម្មនៃយន្តការប្រឆាំងការគេចពន្ធឧបាស្រ័យ នៅក្រោមក្របខ័ណ្ឌអង្គការ WTO ។ មាត្រា១២ នៃសេចក្តីព្រាងច្បាប់ដាំងឃែល (Dunkel Draft) ឆ្នាំ១៩៩១ បានផ្តល់សិទ្ធិដល់ភាគីនីមួយៗ ក្នុងការដំឡើងពន្ធប្រឆាំងការលក់បង្ហូចថ្លៃ ទៅលើសកម្មភាពណាមួយដែលគេចពន្ធឧបាស្រ័យតាមរយៈការផ្ទេរផលិតកម្ម និងការគេចពន្ធឧបាស្រ័យតាមច្រកប្រទេសនាំចូល។ បើទោះជាមានការជំរុញខ្លាំងពីអាម៉េរិក ជាពិសេសការអំពាវនាវឱ្យរឹតបន្តឹងច្បាប់ពាក់ព័ន្ធនឹងយន្តការប្រឆាំងការគេចពន្ធឧបាស្រ័យ តាមរយៈការបញ្ចូលបញ្ញត្តិប្រឆាំងការគេចពន្ធតាមរយៈប្រទេសទីបី និងការគេចពន្ធតាមរយៈការផ្លាស់ប្តូរតិចតួចសណ្ឋាននៃផលិតផល ក៏សេចក្តីព្រាងច្បាប់នេះខ្វះការគាំទ្រផ្នែកនយោបាយ ពីបណ្តាប្រទេសចរចាផ្សេងទៀត រួមទាំងឥណ្ឌាផងដែរ ហើយច្បាប់នេះត្រូវបានភាគីចរចាច្រានចោលតាំងពីមុនឆ្នាំ១៩៩៤មកម្ល៉េះ។

